ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤.សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

www.pheakdeylaw.com

# ស ម្រេ ច

**ប្រការ ១:** ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា ដែលមានរាយនាមដូចខាងក្រោម ÷

១ - ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធាន

២ - ឯកឧត្តម **តោ សឿត** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធានអចិន្ត្រៃយ៍

៣ - ឯកឧត្តម **សត់ សេដ្ឋា** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អនុប្រធាន

៤ - ឯកឧត្តម **សួរ ឡិចធំរ** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៥- ឯកឧត្តម **គីម កុសល** រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុប្រធាន

៦- ឯកឧត្តម **ខឹម ចិសិដ្ឋ** អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៧- ឯកឧត្តម **សុខ្ខ សុធន** អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៨- លោកជំទាវ **គ្រួយ ឈាងស៊ុម** អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល សមាជិក

៩- ឯកឧត្តម **ស៊ាន បូរ៉ាត** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១០- លោកជំទាវ **មាន ស្រីណូ** អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី សមាជិក

១១- ឯកឧត្តម **ស៊ិន សុខ** អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន សមាជិក

១២- ឯកឧត្តម **ជា ថៅយ** អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១៣- ឯកឧត្តម **ស្តើង សុខុម** អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ សមាជិក

១៤- ឯកឧត្តម **ម៉ៅ សម្បត្តិ** អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៥- ឯកឧត្តម **ឌុយ ចំរើន** អនុរដ្ឋលេខាធិការ ក្រសួងផែនការ សមាជិក

១៦- ឯកឧត្តម **កែប ជុតិមា** អភិបាលរាជធានីភ្នំពេញ សមាជិក

www.pheakdeylaw.com

១៧- លោកជំទាវ ញុំ ចន្ទ័នី អគ្គលេខាធិការ កាកបាទក្រហមកម្ពុជា សមាជិក

១៨- អភិបាលខេត្តពាក់ព័ន្ធ សមាជិក។

ប្រការ ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានី អភិបាលខេត្តពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com